កម្ពុជាថ្មី ប្រចាំថ្ងៃ
KAMPUCHEA THMEY DAILY

# អង្គភាពរដ្ឋករទឹកស្អាតនៅមណ្ឌលគិរីដាក់សម្ពោធឱ្យប្រើប្រាស់ជាផ្លូវការហើយ



អង្គភាពរដ្ឋករទឹកស្អាតនៅមណ្ឌលគិរីដាក់សម្ពោធឲ្យប្រើប្រាស់ជាផ្លូវការហើយ

មណ្ឌលគិរី៖ បឹងទំនប់លើ និងបឹងទំនប់ក្រោមក្នុងក្រុងសែនមនោរម្យគឺជាប្រភពទឹកយ៉ាងសំខាន់សម្រាប់ទាញយកមកផ្គត់ផ្គង់ទឹកស្អាតឲ្យពលរដ្ឋប្រើប្រាស់ក្នុងក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី ។

ឯកឧត្តម ចម ប្រសិទ្ធ ថ្លែងយ៉ាងដូច្នេះនៅក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការផ្គត់ផ្គង់ទឹកស្អាតក្នុងក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរីក្រោមហិរញ្ញប្បទានឥតសំណងរបស់រាជរដ្ឋាភិបាលជប៉ុន ជាង ២ លានដុល្លាសហរដ្ឋអាមេរិក ក្នុងក្របខ័ណ្ឌគម្រោងជំនួយអភិវឌ្ឍន៍តំបន់ត្រីកោណ កម្ពុជា-ឡាវ-វៀតណាម កាលពីថ្ងៃទី២៥ មេសា ២០១៦ នៅអង្គភាពរដ្ឋាករទឹកក្នុងក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី ។ ឯកឧត្តមរដ្ឋមន្ត្រីក្រសួងឧស្សាហកម្មនិងសិប្បកម្មបានថ្លែងទៀតថា អជ្ញាធរខេត្ត ជាពិសេសមន្ទីរសាធារណៈការ ត្រូវពិនិត្យមើលលើបញ្ហាប្រព័ន្ធលូបង្ហូរទឹកភ្លៀង និងទឹកកង្វក់ ដើម្បីបញ្ចៀសកុំឲ្យទឹកទាំងនោះហូរចូលទឹកបឹងទំនប់លើ និង បឹងទំនប់ក្រោម ដែលជាប្រភពផ្គត់ផ្គង់ទឹកស្អាត ហើយប្រជាពលរដ្ឋដែលរស់នៅជុំវិញបឹងទាំងពីរនេះក៏ត្រូវចូលរួមថែរក្សា អនាម័យ បរិស្ថាន ជុំវិញបឹងឲ្យបានល្អប្រសើរ ។

ឯកឧត្តមបន្តថា មន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តមណ្ឌលគិរីក៏ត្រូវ សហការជាមួយមន្ទីរជំនាញពាក់ព័ន្ធឲ្យបានល្អ ក្នុងការសាងសង់ពង្រីកបណ្តាញចែកចាយទឹកឲ្យសម្រេចបានជាជំហាន បន្តបន្ទាប់ទៀត ឆ្លើយតបតាមតម្រូវការប្រើប្រាស់របស់ប្រជាពលរដ្ឋក្នុងក្រុងសែនមនោរម្យ ។

លោក តូវ សុផារ៉ា ប្រធានមន្ទីរឧស្សាហកម្មនិងសិប្បកម្មខេត្តមណ្ឌលគិរី បានឲ្យដឹងដែរថា បច្ចុប្បន្ននេះប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតក្នុងក្រុងសែនមនោរម្យ មានសមត្ថភាពផលិតទឹក ២០០០ ម៉ែត្រគីបក្នុងមួយថ្ងៃ និងមានបណ្តាញចែកចាយ ទឹកប្រវែង ជាង២៦គីឡូម៉ែត្រនិងអាចផ្គត់ផ្គត់ទឹកជូនប្រជាពលរដ្ឋបានចំនួន០៣សង្កាត់ ប្រមាណជា៧០%នៃក្រុង ក្នុងនោះមានសង្កាត់មនោរម្យ សង្កាត់ស្ពានមានជ័យ សង្កាត់សុខដុម ដោយឆ្លើយតបតាមតម្រូវការប្រើប្រាស់របស់ពលរដ្ឋ បានចំនួន ១៨៣០ គ្រួសារ ។ លោកប្រធានមន្ទីរឧស្សាហកម្មនិងសិប្បកម្មបន្តថា ថ្វីត្បិតបច្ចុប្បន្នការផ្គត់ផ្គង់ទឹកស្អាតក្នុង ក្រុងសែនមនោមរម្យ មិនទាន់ឆ្លើយតបតាមតម្រូវការ១០០%

នៃការប្រើប្រាស់របស់ប្រជាជន ប៉ុន្តែមន្ទីរឧស្សាហកម្មនិងសិប្បកម្ម ព្រមទាំងអង្គ ភាពទឹកស្អាតខេត្តមណ្ឌលគិរីកំពុងបំពេញសេវ៉ានេះគ្របដណ្តប់សង្កាត់ចំនួន3គឺសង្កាត់ស្ពានមានជ័យ សង្កាត់ សុខដុម និងសង្កាត់
មនោរម្យ ។

សូមជំរាបថា គំរោងសាងសង់អង្គភាពរដ្ឋករទឹកស្អាតនៅក្រុងសែនមនោរម្យនេះបានចាប់ផ្តើមសាងសង់តាំងពីថ្ងៃទី 01.03.2015 លើផ្ទៃដី 1800.48 ម៉ែត្រការ៉េក្នុងក្រុងសែនមនោរម្យបានបញ្ចប់នៅថ្ងៃទី01.04.2016 សាងសង់ដោយក្រុមក្រុមហ៊ុនមៅការ តឹម ម៉ិច ៕ ដារ៉ា